# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបពិភាក្សាការងារជាមួយប្រធានអង្គការ JETRO ជប៉ុន



នៅព្រឹកថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១៤ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រួមនិងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រោមឱវាទក្រសួង បានអញ្ជើញជួបពិភាក្សាការងារជាមួយប្រតិភូអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) ដឹកនាំដោយលោក **Hiroyuki Ishige** ប្រធានអង្គការ JETRO ជប៉ុន នៅទីស្តីការក្រសួង ។






លោក **Hiroyuki Ishige** ប្រធានអង្គការ JETRO នៃប្រទេសជប៉ុន បានជម្រាបជូនពីការរីករាយចំពោះជំនួបថ្ងៃនេះជាមួយឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ដែលជាមិត្តចាស់ដ៏ល្អ ក្នុងការងារ ។ លោកប្រធាន បានបញ្ជាក់ថា៖ វត្តមានការិយាល័យអង្គការ JETRO នៅកម្ពុជា នៅឆ្នាំ២០១០ គឺកើតឡើងដោយការជម្រុញ និងការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ។ ជាពិសេសជាងនេះទៀត ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ជាឥស្សរៈជនកម្ពុជាមួយរូប ដែលក្នុងអតីតជាទេសរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CDC បានដើរតួយ៉ាងសំខាន់ ក្នុងការទាក់ទាញអ្នកវិនិយោគទុនជប៉ុនមកកម្ពុជា តាមរយៈបទឧទ្ទេសនាម ក្នុងសិក្ខាសាលា និងកិច្ចប្រជុំនានា ទាំងក្នុង និងក្រៅប្រទេស ។ លោកប្រធានអង្គការ JETRO បានជម្រាបជូនពីសកម្មភាពការងាររបស់អង្គការJETRO ដែលបានធ្វើយ៉ាងសកម្មក្នុងការទាក់ទាញ និងប្រឹក្សាជាមួយក្រុមហ៊ុនជប៉ុន ដែលត្រូវធ្វើការសម្រេចចិត្តក្នុងការបណ្តាក់ទុននៅក្រៅប្រទេស ។ ក្នុងនោះការិយាល័យអង្គការ JETRO ប្រចាំកម្ពុជា នៅឆ្នាំនេះ មានក្រុមហ៊ុនចំនួន ១៣២ ដែលបានមកធ្វើការពិភាក្សា និងពិគ្រោះយោបល់ ។ ក្នុងគោលបំណងនៃជំនួបពិភាក្សានេះ លោកប្រធានអង្គការ JETRO ជប៉ុន បានលើកឡើងពីសារៈសំខាន់ របស់សហគ្រាសខ្នាតតូច និងមធ្យម នៅក្នុងប្រព័ន្ធសេដ្ឋកិច្ច ហើយប្រទេសកម្ពុជា កំពុងមានការរីកចម្រើនលើវិស័យនេះ និងជាការយកចិត្តទុកដាក់របស់អង្គការ JETROផងដែរ ។




ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសំដែងការស្វាគមន៍ និងបានថ្លែអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះអង្គការ JETRO ជប៉ុន ប្រចាំកម្ពុជា ដែលរយៈពេល០៤ ឆ្នាំកន្លងទៅនេះ បានធ្វើសកម្មភាពយ៉ាងសកម្ម ក្នុងការជួយទាក់ទាញក្រុមហ៊ុនជប៉ុន ក្នុងការសម្រេចចិត្តមកបណ្តាក់ទុននៅកម្ពុជា ដែលបច្ចុប្បន្នវត្តមានក្រុមហ៊ុនជប៉ុនកាន់តែមានចំនួនច្រើនឡើងនៅកម្ពុជា ។ កត្តានេះដោយសារការផ្តល់ព័ត៌មានចេញពីអង្គការ JETRO ជាព័ត៌មានដែលអាចទុកចិត្តបាន ។ ឯកឧត្តមក៏បានថ្លែងអំណរគុណចំពោះ ការិយាល័យអង្គការ JETRO ប្រចាំប្រទេសថៃ និងប្រទេសចិន ដែលបានជួយទាក់ទាញក្រុមហ៊ុនជប៉ុនមកកម្ពុជា តាមរយៈការបង្ហាញពីសក្តានុពល និងលក្ខណៈអំណោយផលល្អប្រសើររបស់កម្ពុជា ។

ចំពោះទំនាក់ទំនងដ៏ល្អដែលធ្លាប់មានរវាង អង្គការ JETRO និងក្រសួងពាណិជ្ជកម្ម ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើឱ្យរក្សាបន្តទំនាក់ទំនងនេះទៅមុខទៀតកាន់តែប្រសើរ ហើយឯកឧត្តមមានការីករាយដែលអង្គការ JETRO បានយកចិត្តទុកដាក់ចំពោះការជម្រុញការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា ដែលមានជាង៥សែនមូលដ្ឋាន ទូទាំងប្រទេស ។ ទាក់ទងកិច្ចការនេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានស្នើឱ្យ អង្គការ JETRO ជួយជំនួយបច្ចេកទេសដល់កម្ពុជា ដូចជាៈជួយលើផ្នែកគ្រប់គ្រងការចុះបញ្ជីសហគ្រាសខ្នាតតូច និងមធ្យម តាមប្រព័ន្ធអេឡិចត្រូនិក ។ ពីព្រោះក្នុងចំណោម ជាង៥សែនមូលដ្ឋាន កម្ពុជា ទើបចុះបញ្ជីបាន ប្រមាណ២ម៉ឺនមូលដ្ឋានប៉ុណ្ណោះ - ការស្នើឱ្យមានការផ្លាស់ប្តូរទស្សនៈកិច្ចរឺជំនួបពិភាក្សាចាប់ដៃគូរវាងសគ្រាសខ្នាតតូច និងមធ្យម កម្ពុជា ជាមួយ ជប៉ុន ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងចែករំលែកជំនាញគ្រប់គ្រង ។ ទាក់ទង និងការជម្រុញផលិតកម្មសូត្រ និងស្ករត្នោត ដែលកន្លងមកអង្គការ JETRO បានគាំទ្រឱ្យមានការបើកច្រកទីផ្សារនៅជប៉ុន ភាគីទាំងពីរ នឹងខិតខំសហការរួមគ្នា ជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីពង្រីកសក្តានុពលនាំចេញ ។ ចំពោះសំណើរខាងលើរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** អង្គការ JETRO ចាត់ទុកថាមានសារៈសំខាន់ សម្រាប់ជួយឱ្យសហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា មានភាពរឹងមាំឡើង ក្នុងការចូលរួមសមាហរណកម្មអាស៊ាន ឆ្នាំ២០១៥ ខាងមុខ ។

